# ផែនការរៀបចំមេរៀនសំរាប់គ្រូ

សូមពិនិត្យមើលទំព័រ១ និង ២ នៃ "របៀបក្នុងការប្រើសៀវភៅរបស់គ្រូនេះ" សំរាប់ព័ត៌មានអំពីការប្រើនៃផែនការនៃការរៀបចំមេរៀនទាំងនេះ

# បញ្ជីរាយកិច្ចការនៅក្នុងថ្នាក់

ចំណេះដឹងមុខវិជ្ជា: ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងមនុស្សដទៃទៀត

**ការប្រលង** ខគម្ពីរត្រូវចងចាំ ថ្ងៃខែឆ្នាំ

១. ភីលីព ៤:៨ ថ្ងៃទី២

២. ម៉ាថាយ ១៩:៤ ថ្ងៃទី៣

៣. ____

**គំរោងកិច្ច** ថ្ងៃខែឆ្នាំ

១. ថ្ងៃទី១

២. ថ្ងៃទី២

៣. ថ្ងៃទី៣

៤. ថ្ងៃទី៤

៥. ____

**ការប្រលងធំ** ថ្ងៃខែឆ្នាំ ថ្ងៃទី៥

# មេរៀនទី១

## មិត្តភ័ក្តិ

**១. សេចក្តីពិតដែលគន្លឹះនៅក្នុងព្រះគម្ពីរ**

ជំហ៊ានដំបូងក្នុងការកសាងមិត្តភាពដែលមានលក្ខណៈសុវត្ថិភាពគឺ ការបង្កើតវិធីសាមញ្ញានានានៃការបំពេញការទទួលខុសត្រូវក្នុងនាមជាមិត្តិសំលាញ់

**២. ខគម្ពីរជាគន្លឹះ ភីលីព៤:៨**

ឱបងប្អូនដែលគ្រីស្ទបរិសទ័អើយ ចូររក្សាគំនិតរបស់បងប្អូន គិតតែពីអ្វីៗដែលជាសេចក្តីពិត អ្វីៗដែលគួរអោយគោរព អ្វីៗដែលត្រឹមត្រូវ អ្វីៗដែលបរិសុទ្ធ និង អ្វីៗដែលជាការគិតល្អស្តីពីអ្វីមួយ ។ ប្រសិនបើមានអ្វីមួយល្អ និង មានតំលៃក្នុងការថ្លែងអំណរគុណ និង ចូរគិតតែពីអ្វីៗស្តីអំពីកិច្ចការទាំងនេះចុះ ។

**៣. សំភារៈយោងសំរាប់សិស្ស**

ទំព័រ២-៥ នៃសៀវភៅសំរាប់សិស្សមានភ្ជាប់មកជាមួយនឹងមេរៀននេះ ។ គំរោងកិច្ចទី១នៅក្នុងសៀវភៅណែនាំក៏នឹងត្រូវបានយកមកប្រើផងមកទាល់សព្វថ្ងៃនេះ ។

**៤. របៀបធ្វើជាមិត្តដ៏ល្អម្នាក់ (៥-១០នាទី)**

ចាប់ផ្តើមថ្នាក់រៀនដោយការពិភាក្សានៅចំនុច ក "តើខ្ញុំអាចក្លាយជាមិត្តដ៏ល្អម្នាក់បានដោយរបៀបណា?" សូមអោយសិស្សចែកចាយពីចំលើយរបស់ពួកគេខ្លះពីគំរោងកិច្ចទី១ សំនួរទី១ និង ទី២ ។

**៥. លក្ខណៈសម្បត្តិមិត្តដ៏ល្អម្នាក់**

មានសិស្សខ្លះអាចនឹងមានការលំបាកក្នុងការមកជាមួយនឹងគំនិតស្តីពីលក្ខណៈសម្បត្តិជាក់លាក់នានាដែលទាក់ទងនឹងមិត្តដ៏ល្អម្នាក់ ។ អ្នកប្រហែលជាអាចឱ្យពួកគេគិតពីមិត្តភ័ក្តិបច្ចុប្បន្នដែលពួកគេមាន ហើយគិតថាជាមិត្តដ៏ល្អម្នាក់ ។ (មានសិស្សមួយចំនួនស្ទាក់ស្ទើរក្នុងការធ្វើកិច្ចការនេះ) ។ សូមអោយសិស្សម្នាក់ៗជ្រើសរើមនុស្សម្នាក់នៅក្នុងគំនិតរបស់គាត់ ។ គាត់មិនចាំបាច់ប្រាប់នរណាម្នាក់ឡើយ ថាតើមិត្តម្នាក់នោះជានរណាឡើយ ។

ក្រោយពីសិស្សម្នាក់ៗបានជ្រើសរើមនុស្សម្នាក់ដែលខ្លួនគេគិតថា ជាមិត្តដ៏ល្អម្នាក់របស់ពួកគេរួចហើយ បន្ទាប់មកសូមអោយពួកគេឆ្លើយទៅនឹងសំនួរទាំងនេះដែលជាប់ទាក់ទងទៅនឹងមិត្តម្នាក់នោះ ។

ក. តើមានចំនុចល្អអ្វីៗ ដែលធ្វើឱ្យមិត្តនោះក្លាយជាមិត្តដ៏ល្អម្នាក់?

ខ. តើបញ្ហាអ្វី ដែលនាំអោយបំផ្លាញដល់ទំនាក់ទំនងមិត្តភាពនេះបាន?

**៦. ប្រភេទ៤យ៉ាងនៃមិត្តភាព (១០នាទី)**

សូមចូរទៅចំនុច ខ "ប្រភេទផ្សេងគ្នានៃមិត្តភាព" សូមប្រញាប់បញ្ចាប់បួនប្រភេទផ្សេងគ្នានៃមិត្តភាពនេះ ។

**៧. ការបង្កើតមិត្តភាព (៣០នាទី)**

សូមត្រឡប់ទៅកាន់ប្រភេទពីរនៃមិត្តភាពដំបូងសិន ហើយចំណាយពេលប្រហែលជា៣០នាទីពិភាក្សាអំពីចំនុចទាំងនេះ ។ ចូរពិភាក្សារបៀបដែលពួកគេចាប់ផ្ដើមអភិវឌ្ឍន៍នូវប្រទេភផ្សេង១គ្នានៃចំណងមិត្តភាពទាំងនេះ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេនៅសព្វថ្ងៃនេះ

**៨. ការអនុវត្តសំរាប់ជីវិតផ្ទាល់ខ្លួន**

ចូរផ្ដោតលើការយកមេរៀនទៅអនុវត្តផ្ទាល់ខ្លួន ដោយពិចារណាលើសេចក្ដីពិតជាគន្លឹះក្នុងព្រះ គម្ពីរ និង ខគម្ពីរជាគន្លឹះសំរាប់សព្វថ្ងៃនេះ ។ ចូរភ្ជាប់ចំនុចទាំងនេះទៅនឹងការទទួលខុសត្រូវ នៃកំរិតទាំងពីរនៃមិត្តភាព ។

**៩. កិច្ចការក្នុងថ្នាក់រៀន**

ក. ដាក់ចំណាត់ថ្នាក់លើគំរោងកិច្ចការទី១ នៅចុងបញ្ចាប់នៃថ្នាក់រៀននេះ

ខ. ចែកក្រដាសមេរៀននៃសៀវភៅសំរាប់សិស្ស ប្រសិនបើអ្នកមិនទាន់បានធ្វើវា

## មេរៀនទី១
### កំណត់ត្រាអំពីប្រវត្តមេរៀន

ទាំងនេះគឺជាចំលើយចេញពីព្រះគម្ពីរសំរាប់សំនួរដំបូងពីរដែលបានរាយនៅលើគំរោងកិច្ចទី១ ។ អ្នកប្រហែលជាត្រូវការប្រើខគម្ពីរមួយចំនួនទាំងនេះនៅក្នុងថ្នាក់សំរាប់ពិភាក្សា ប្រសិនបើអ្នកមានពេល

**ក. ចូររាយនូវចំនុចល្អៗដែលនិយាយពីមិត្តភ័ក្តិ**

ភីលីព ២:៤ "... ចូរអរសប្បាយ ដែលបានដឹងថា នូវអ្វីដែលមនុស្សដ៏ទៃទៀតកំពុងធ្វើ"

សុភាសិត ១៧:១៧ "មិត្តភ័ក្តិស្រលាញ់គ្រប់ពេលទាំងអស់..."

សុភាសិត ១២:២៥ "ការរងទុក្ខដែលគ្របសង្កត់ចិត្ត នោះធ្វើឱ្យរួញថយចុះ តែពាក្យល្អ១ម៉ាត់នឹងធ្វើឱ្យរីករាយឡើង ។

សុភាសិត ១២:២៦ "មនុស្សឆ្លាតសុំយោបល់ពីមិត្តភ័ក្តិ..."

**២. បញ្ហាលបណ្តាលអោយបំផ្លាញចំណងមិត្តភាព**

សុភាសិត ១៦:២៨ "... ការនិយាយដើមនាំមកនូវការបែកបាក់មិត្តភាព"

សុភាសិត ១៧:៩ "សេចក្តីស្រលាញ់បំភ្លេចចោលនូវកំហុស រីការនិយាយច្រំដែលៗនាំមកនូវការបែកបាក់មិត្តសំលាញ់" ។

ម៉ាថាយ ៥:២៣-២៤ "ប្រសិនបើអ្នករាល់គ្នានាំយកដង្វាយរបស់អ្នករាល់គ្នាមកកាន់អស្នារ ហើយបានដឹងថាមានបងប្អូនម្នាក់ដែលប្រឆាំងទាស់នឹងគេ (២៤) ចូរទុកដង្វាយរបស់សិន រួចទៅស្រុះស្រួលរវាងអ្នក និង គាត់ រួចហើយសឹមមកថ្វាយដង្វាយរបស់អ្នកវិញ ។

ភីលីព ៤:២ "ខ្ញុំសូមទូន្មានដល់នាងអើរ៉ូឌា និងនាងស៊ុនទីចដែរ ឱ្យមូលគំនិតតែ១ក្នុងព្រះអម្ចាស់ សូមឈប់ឈ្លោះប្រកែកគ្នាទៀតទៅ តែត្រូវរួបរួមគ្នាជាមិត្តដ៏ល្អវិញ ។

១ថេស្សាឡូនិច ២:៥ "ដ្បិតយើងខ្ញុំមិនដែលប្រើពាក្យបញ្ចើច ដូចជាអ្នករាល់គ្នាដឹងស្រាប់ ឬប្រព្រឹត្តដោយចិត្តលោភឡើយ សឹងមានព្រះទ្រង់ជាសាក្សីហើយ

២ធីម៉ូថេ ៣:២-៦ "(២)ដ្បិតនៅគ្រានោះមនុស្សនឹងស្រលាញ់តែខ្លួនឯង ទាំងស្រលាញ់ប្រាក់ អួតអាងគឃរ មានឫកខ្ពស់ ប្រមាថមើលងាយ (៣)មិនស្រលាញ់តាមធម្មតា មនុស្សគ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ (៤) ក្បត់គេ ឥតបើគិត មានចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ (៥)គេមានឫកពាជាអ្នកគោរពប្រត្តិបត្តិដល់ព្រះ ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្តា ដែលមកដោយការគោរពប្រត្តិបត្តិនោះទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ (៦) ដ្បិតមនុស្សទាំងនោះ ជាពួកអ្នក

ដែលចូលទៅក្នុងផ្ទះគេទាំងល្បួងនាំពួកស្រី១ដែលល្ងង់ឱ្យឈ្លក់ចិត្ត ដែលស្រ្តីទាំងនោះផ្ទុកធ្ងន់ដោយអំពើបាបហើយ ក៏បណ្ដោយតាមសេចក្ដីប៉ងប្រាថ្នា១ ។

យ៉ាកុប ២:១៥-១៦ "(១៥) ចុះបើមានបងប្អូនប្រុសស្រីណានៅអាក្រាត ព្រមទាំងខ្វះអាហារបរិភោគរាល់តែថ្ងៃ (១៦) ហើយអ្នករាល់គ្នាណាមួយនិយាយទៅអ្នកនោះថា អញ្ជើញទៅអោយសុខសាន្ត សូមឱ្យបានកក់ក្ដៅ ហើយឆ្អែតចុះ តែគ្មានឱ្យអ្វីដល់អ្នកដែលត្រូវការខាងរូបសាច់នោះសោះ នោះតើមានប្រយោជន៏អ្វី

# មេរៀនទី២

## មិត្តភ័ក្តិ

### ១. សេចក្តីពិតដែលគន្លឹះនៅក្នុងព្រះគម្ពីរ

បង្កើតនូវវិធីជាក់ស្តែងនៃការបង្ហាញសេចក្តីស្រលាញ់ គឺជាកត្តាដ៏មានសារសំខាន់បំផុតដែលខ្ញុំអាចកសាងមិត្តភាពដ៏ល្អបាន ។

### ២. ខគម្ពីរគន្លឹះ ១កូរិនថូស ១៣:៧

ប្រសិនបើអ្នកស្រលាញ់នរណាម្នាក់ អ្នកនឹងមានភក្តីភាពចំពោះម្នាក់នោះ មិនខ្វល់ថានឹងមានបញ្ហាអ្វីដោយ ។ អ្នកនឹងតែងតែជឿជាក់លើម្នាក់នោះ តែងតែរំពឹងគិតពីអ្វីដែលល្អចេញពីម្នាក់នោះ និង តែងតែឈរជួយការពារដល់ម្នាក់នោះពេលមានបញ្ហា ។

### ៣. សំភារៈសិក្សាយោងសំរាប់សិស្ស

ទំព័រ៦-៩នៃសៀវភៅសិស្សមានភ្ជាប់ជាមួយនៅក្នុងមេរៀននេះ

### ៤. មាន៤ប្រភេទនៃមិត្តភាព (៥-១០នាទី)

សូមចំណាយពេលរំលឹកនូវប្រភេទទាំង៤យ៉ាងនៃមិត្តភាពនេះ

### ៥. មិត្តភ័ក្តិរបស់អ្នក

សូមឱ្យពួកគេគំរោងកិច្ចទី១ចេញនៅក្នុងចំនុចនេះ ដូច្នេះពួកគេអាចប្រើចំលើយរបស់ពួកគេដើម្បីយកមកពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

### ៦. ទំនុកចិត្ត និង មិត្តភាព (១០-១៥នាទី)

ចូរពិភាក្សានូវសំរាប់ទី៤ក្នុងគំរោងកិច្ចទី១ ។ ចូរព្យាយាមឱ្យជាឧទាហរណ៏ខ្លះ១ នៃផលលំបាកមួយចំនួនក្នុងការកសាងទំនុកចិត្តតាមការទំនាក់ទំនងជាមួយមនុស្សដ៏ទៃទៀត ជាពិសេសសិស្សដែលទើបតែបានទទួលការសង្គ្រោះចេញពីផុតការប្រើប្រាស់ ថ្នាំញៀន ឬក៏មាន

សាវតាប្រហាក់ប្រហែលគ្នា ។ អ្នកប្រហែលជាចង់ជជែកគ្នាផងដែរ ស្តីពីការកសាងមិត្តភាព ដែលស៊ីជុំរៅជាមួយសមាជិកក្រុមគ្រួសារក្នុងចំនុចនេះ ។ នេះអាចជាបញ្ហាដ៏លំបាកខ្លះសំរាប់មនុស្សមួយចំនួន ។

## ៧. របៀបធ្វើជាមិត្តដ៏ល្អ (៥-១៥នាទី)

សូមពិភាក្សាសំនួរទី៥ពីក្នុងគំរោងកិច្ចការទី១ ។ អ្នកប្រហែលចង់អោយជាឧទាហរណ៍មួយ រឺ ពីរស្តីពីអ្វីទៅដែលជាគ្រីស្ទបរិសទ័ថ្មីៗ (ឬ សិស្សពីមុនៗ) ដែលធ្វើរួចរាល់ហើយ ជាពិសេស ប្រសិនបើសិស្សស្ទាក់ស្ទើក្នុងការពិភាក្សាពីចំលើយរបស់ពួកគេ ។ ចូរប្រមូលការពិភាក្សាជាក្រុមធំ ស្តីពីរបៀបដែលពួកគេអាចធ្វិការផ្លាស់ប្តូរយ៉ាងណាខ្លះបាន ។

## ៨. មិត្តភ័ក្តិដែលមិនមែនជាគ្រីស្ទបរិស័ទ (៥-១៥នាទី)

សូមពិភាក្សាលើប្រធានបទ ថាតើត្រូវធ្វើយ៉ាងណាខ្លះចំពោះមិត្តភ័ក្តិចាស់ៗ--ជាពិសេសមិត្តភ័ក្តិដែលមិនមែនជាគ្រីស្ទបរិសទ័ ។ សូមប្រើសំភារៈសិក្សានៅទំព័រទី៩នៃសៀវភៅ សិស្ស ។ វិញទៀតសូមពិភាក្សានូវចំលើយរបស់ពួកគេទៅនឹងសំនួរទី៣ក្នុងគំរោងកិច្ច ការទី១ ។

## ៩. ការអនុវត្តន៏សំរាប់ផ្ទាល់ខ្លួន

សំរាប់ការអនុវត្តន៏នៅថ្ងៃនេះ សូមអោយពួកគេបង្កើតនូវតារាងរាយនូវកិច្ចការមួយចំនួនដែលធ្វើអោយមានពិបាកក្នុងការបង្កើតមិត្តភាពជាមួយមនុស្សដ៏ទៃផ្សេងទៀត ដែលឥឡូវនេះពួកគេរស់នៅជាមួ ឬក៏ ជាមួយមនុស្សដែលនៅក្នុងក្រុមជំនុំដែលពួកគេទៅថ្វាយបង្គំ ។ ហើយឱ្យពួកគេសរសេរចុះនូវរឿងមួយ ដែលពួកគេអាចធ្វើបាន ដើម្បីអោយក្លាយទៅជាមិត្តដ៏ល្អបាន

## ១០. កិច្ចការក្នុងថ្នាក់

ក. ដាក់ប្រលងតូចមួយក្នុងគម្ពីរ ភីលីព៤:៨ នៅពេលបញ្ចប់ថ្នាក់រៀន

ខ. សូមពន្យល់គំរោងកិច្ចការទី២ និង ទី៣ ។ ពួកគេត្រូវបំពេញអោយបានចប់មុនពេលសិក្សានូវមេរៀនបន្ទាប់ (មេរៀនទី៣) ។

## មេរៀនទី៣

### ការណាត់ជួបរវាងប្រុស និង ស្រី

**១. សេចក្ដីពិតដែលគន្លឹះនៅក្នុងព្រះគម្ពីរ**

ក្នុងនាមជាគ្រីស្ទបរិស័ទ ខ្ញុំត្រូវបង្កើតនូវខ្នាតគំរូផ្ទាល់ខ្លួនសំរាប់ខ្ញុំ ដើម្បីណែនាំខ្ញុំក្នុងការណាត់ជួបរបស់ខ្ញុំ រវាងប្រុស និងស្រី ។

**២. ខគម្ពីរគន្លឹះ អេភេសូ ៥:១៥,១៧**

(១៥) "ដូច្នេះត្រូវប្រយត្ន័ដោយមធ្យ័ត ដែលអ្នករាល់គ្នាដើរយ៉ាងណា កុំអោយដើរដូចជាមនុស្សឥតប្រាជ្ញាឡើយ ត្រូវតែដើរដោយមានប្រាជ្ញាវិញ ។(១៧) ដូច្នេះកុំអោយខ្លៅល្ងង់ឡើយ ត្រូវខំអោយយល់បំណងព្រះហឫទ័យព្រះអម្ចាស់វិញ ។"

**៣. សំភារៈសិក្សាយោងសំរាប់សិស្ស**

នៅទំព័រ ៧ និង ៨ នៅក្នុងសៀវភៅសិស្សមានភ្ជាប់មកជាមួយនៅក្នុងមេរៀននេះ

**៤. ការរួមភេទ និង ជីវិតរបស់គ្រីស្ទបរិសទ័ (៥-១០នាទី)**

សូមយកពេល ៥-១០នាទី ដើម្បីណែនាំនូវមេរៀបពាក់កណ្ដាលចុងក្រោយនេះស្ដីពី "ការរួមភេទ និង ជីវិតរបស់គ្រីស្ទបរិសទ្" សូមមើលកំណត់ត្រារបស់គ្រូ ដែលអាចផ្ដល់នូវព័តិមាន និង សំនួរនៅទីនេះបាន ។ ទំព័រទី១១នៃសៀវភៅសិស្សក៏បានផ្ដល់ផងដែរ នូវសំនួរខ្លះៗ ។ កុំព្យាយាមឆ្លើយនូវសំនួរទាំងអស់នេះនៅពេលឥឡូវនេះ គឺគ្រាន់តែលើកសំនួរទាំងនេះ និង ពន្យល់ថា យើងនឹងពិភាក្សាវានៅពេលបញ្ចប់មេរៀននេះទាំងមូល ។

**៥. តើហេតុអ្វីបានជាត្រូវមានការណាត់ជួបរវាងប្រុស និង ស្រី? (៥-១០)នាទី**

សូមពិភាក្សាសំនួរទីមួយចេញពីគំរោងកិច្ចការទី២ ស្ដីពីការណាត់ជួបរវាងប្រុស និង ស្រី ។ សូមរាយនូវចំលើយដែលសិស្សផ្ដល់អោយ ។ សូមមើលទំព័រទី១២នៃសៀវភៅសិស្សសំរាប់ចំលើយដែលគិតថាអាចទទួលយកបាន ។ សូមបន្ថែមនូវចំលើយខាងក្រោម ប្រសិនបើគ្មាននរណាម្នាក់មិនឆ្លើយវាកើត ។ "ដើម្បីរៀនពីរបៀបផ្ដល់សេចក្ដីស្រលាញ់របស់ព្រះអម្ចាស់ (សេចក្ដីស្រលាញ់អាកាពេ) ទៅកាន់មនុស្សដែលមានភេទផ្ទុយគ្នា"

**៦. តើអ្នកត្រៀមខ្លួនរួចរាល់ហើយ ឬនៅ? (៥-១៥នាទី)**

សូមពិភាក្សាសំនួរទី២បន្ទាប់ទៀតពីគំរោងកិច្ចការទី២ ។ ក្រោយពីពួកគេបានចែកចាយនូវចំលើយរបស់ពួកគេ បន្ទាប់មកផ្ដល់នូវគំនិតដែលមានរាយនៅទំព័រទី១២នៃសៀវភៅរបស់សិស្ស ។ សូមអោយឧទាហរណ៏ខ្លះៗ នៃគំរូខ្នាត រឺ ស្តង់ដា ដែលសមរម្យសំរាប់គ្រីសបរិសទ័ ។

**៧. ការបង្កើតនូវសេចក្តីស្រលាញ់ (៥-១០នាទី)**

សូមចំណាយពេលបន្តិច ដើម្បីបង្ហាញនូវតារាងស្តីពី របៀបដើម្បីបង្កើតនូវសេចក្តីស្រលាញ់ ។ សូមមើល កំណត់ត្រារបស់គ្រូ សំរាប់ព័តិមានបន្ថែមស្តីពីចំនុចនេះ ។

**៨. ការបំផ្លាញនូវសេចក្តីស្រលាញ់ (៥-១៥នាទី)**

បន្ទាប់មកសូមបង្ហាញនូវតារាង ដែលមានចំណងជើង "របៀបក្នុងការបំផ្លាញសេចក្តីស្រលាញ់អាកាពេ" សូមមើលកំណាត់ត្រារបស់គ្រូ សំរាប់ព័តិមានបន្ថែមស្តីពីចំនុចនេះ ។

**៩. គំរូខ្នាត រឺ ស្តង់ដាសំរាប់ការណាត់ជួបរវាងប្រុស និង ស្រី**

សូមចំណាយពេលបន្តិចដើម្បីពិភាក្សានៅក្នុងថ្នាក់ ស្តីពីគំរូស្តង់ដាមួយចំនួន ដែលពួកគេអាចកំណត់បានសំរាប់ការណាត់ជួបរវាងប្រុស និង ស្រី ។

**១១. ផលប្រយោជន៏ និង គ្រោះថ្នាក់នៃការណាត់ជួបរវាងប្រុស និង ស្រី**

ប្រសិនបើអ្នកមានពេល សូមពិភាក្សាសំនួរទី៣ ៤ និង ៥ពីគំរោងកិច្ចការ២ ស្តីពីការណាត់ជួបគ្នារវាងប្រុស និង ស្រី ។

**១២. ការអនុវត្តន៏សំរាប់ផ្ទាល់ខ្លួន**

សំរាប់ការអនុវត្តន៏ផ្ទាល់ខ្លួននៅថ្ងៃនេះ គឺឱ្យពួកគេសរសេរចូលនូវគំរស្តង់ដាផ្ទាល់ខ្លួនរបស់ពួកគេសំរាប់ការណាត់ជួបគ្នារវាងប្រុស និង ស្រី ។ សូមជំរុញអោយពួកគេរកខគម្ពីរមួយចំនួនដែលនិយាយអំពីស្តង់ដានីមួយៗ ។ សូមលើកទឹកចិត្តពួកគេអោយចងចាំខទាំងនេះ ។ម្តងទៀតសូមរំលឹកសិស្សដែលបានរៀបការរួចហើយ ពីរបៀបដែលពួកគេអាចប្រើមេរៀននេះបាន

**១៣. កិច្ចការក្នុងថ្នាក់**

ក. ដាក់ពិន្ទុ និង ចំណាត់ថ្នាក់លើគំរោងកិច្ចការទី ២ និង ៣ នៅចុងបញ្ចប់ថ្នាក់រៀន

ខ. ដាក់ប្រលងតូចមួយស្តីពី គម្ពីរ ម៉ាថាយ ១៩:៥ នៅចុងបញ្ចប់ថ្នាក់រៀន

## មេរៀនទី៣

### ប្រវិត្តកំណត់ត្រាស្តីពី

### ការរួមភេទ និង ជីវិតគ្រីស្ទបរិស័ទ

នៅពេលអ្នកចាប់ផ្តើមបង្រៀននៅក្នុងផ្នែកនេះ អ្នកត្រូវតែប្រុងប្រយត្ន័ក្នុងការកំណត់បរិយាកាសដ៏សមរម្យមួយសំរាប់រយៈពេលបង្រៀននៅក្នុងថ្នាក់ ។ សិស្សរបស់អ្នកនឹងមានចំណាប់អារម្មណ៏យ៉ាងខ្លាំងទៅលើប្រធានបទនេះណាស់ ។ ចំនុចជាគន្លឹះគឺ ធ្វើយ៉ាងណាអោយវាជាឧបករណ៏ដល់ចំណាប់អារម្មណ៏របស់ពួកគេ ដើម្បីជំរុញអោយមាននូវសកម្មភាពរស់រវើកនៅក្នុងថ្នាក់ ក៏ដូចជានៅក្នុងផ្នែកនីមួយៗនៃជីវិតរបស់ពួកគេ ។

គោលគំនិតដែលអ្នកប្រហែលជាបង្ហាញនឹងមានការខុសគ្នាទាំងស្រុងពីអ្វីផ្សេងៗ ដែលពួកគេពុំធ្លាប់បានលឺពីមុនមកទេ ។ មានសិស្សមួយចំនួនប្រហែលជានឹងមិនយល់ព្រមនូវអ្វីដែលអ្នកនិយាយទេ ។ ចូរអោយពួកគេមិនយល់ព្រមទៅចុះ ។ កុំអោយព្យាយាមតឹងតែង ប្រសិនបើពួកគេមិនទាន់ទទួលនូវអ្វីដែលអ្នកត្រូវនិយាយ ។ សូមអនុញ្ញាត្តិអោយព្រះវិញ្ញាណដ៏វិសុទ្ធបើសំដែងសេចក្តីពិតទាំងនេះចូលទៅកាន់ជីវិតរបស់ពួកគេវិញ ។ កិច្ចការដែលអ្នកត្រូវធ្វើសំខាន់បំផុតនោះគឺ បង្ហាញនូវរូបភាពមួយដ៏ស្មោះត្រង់នូវអ្វីដែលការរួមភេទដើរតួរនាទីនៅក្នុងជីវិតរបស់គ្រីស្ទបរិសទ័ ។

ដោយព្រោះអ្នកមានពេលត្រឹមតែពីរថ្ងៃប៉ុណ្ណោះសំរាប់បង្រៀនផ្នែកនេះ នោះអ្នកនឹងមិនអាចចំណាយពេលវេលាដើម្បីពន្យល់ណែនាំដល់សិស្សគ្រប់ទាំងចំនុចទាំងអស់បានទេ ។ ដូច្នេះពេលអ្នកបង្រៀនសេចក្តីទាំងនេះ សូមប្រាប់ពួកគេថា អ្នកនឹងព្យាយាមចំណាយពេលស៊ីជុំរៅទៅលើប្រធានបទស្តីពី ការណាត់ជួបគ្នារវាងប្រុស និង ស្រី និង ការរៀបអាពាហ៏ពិពាហ៏ ។ ហើយនៅសប្តាហ៏ក្រោយៗ ពួកគេនឹងមានឱកាសដើម្បីសិក្សាលើប្រធានបទទាំងនេះតាមបែបពិស្តារ ។

មកដល់ចំនុចនេះ អ្នកប្រហែលជាចង់ណែនាំនូវនិយមន័យនៃសេរីភាពខាងផ្លូវភេទ ។ (និយមន័យនេះគឺផ្អែកទៅលើកំណត់ត្រា ដែលដក់ស្រង់ចេញពី វិទ្យាស្ថានសិក្ខាសាលាដោះស្រាយជំលោះដល់យុវជន ។)

សេរីភាពផ្លូវភេទ--វាមិនមានន័យថាអ្នកអាចធ្វើអ្វីៗបានគ្រប់យ៉ាង តាមតែអ្នកចង់ជាមួយប្រពន្ធ រឺ មិត្តស្រីរបស់អ្នកនោះទេ (ប្តី រឺ មិត្តប្រុស) ។ វាជាអំណាចមួយដែលអ្នកអាចនូវរឿងដ៏ត្រឹមត្រូវ ដែលអ្នកដឹងថាវាជាត្រឹមត្រូវជាមួយនឹងប្រពន្ធ ឬ មិត្តស្រីរបស់អ្នក (ប្តី រឺ ប្រពន្ធ) ។ អ្នកទទួលអំណាចនេះ និង ការយល់ដឹងពីព្រះអម្ចាស់ និង ព្រះបន្ទូលរបស់ទ្រង់ ។

## សំនួរ

១. តើកន្លែងណាមួយ ដែលការរួមភេទមាននៅក្នុងជីវិតរបស់គ្រីស្ទបរិសទ័?

២. តើអ្នកចង់ស្វែងរកអោយឃើញពីរបៀបមានការណាត់ជួបដ៏ជោគជ័យមួយបាន រៀងរាល់ពេលដែលអ្នកមានការណាត់ជួបរវាងប្រុស និង ស្រី ដែរឬទេ?

៣. តើអ្នកត្រូវប្រាកដប្រជាដោយរបៀបណាខ្លះ រៀងរាល់ពេលដែលអ្នកមានណាត់ជួបរវាង អ្នក និង ស្រីនោះ រឺអ្នកសុំស្រីនោះទៅក្រៅជាមួយអ្នក? (ឬទទួលយកការណាត់ជួបពីបុរសនោះឬទេ?)

៤. តើមានអ្វីខ្លះ ដែលធ្វើអោយការណាត់ជួបរវាងប្រុស និង ស្រីទទួលបានជោគជ័យ?

៥. តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីខ្លះ ទាក់ទងទៅនឹងការមានណាត់ជួបដ៏ល្អ?

៦. តើអ្នករៀបការហើយឬនៅ? ប្រសិនបើ ពួកគេបានរៀបការហើយ សូមប្រាប់ពួកគេ ឱ្យប្រើសំភារៈសិក្សានេះនៅក្នុងវិធី៣ផ្សេងៗពីគ្នាដូចជា:

   ក. បង្រៀនកូនរបស់ពួកគេអំពីការណាត់ជួបដ៏ត្រឹមត្រូវ

   ខ. ចែកចាយជាមួយនឹងយុវជន និង យុវនារីក្មេងៗ ដែលមកកាន់ពួកគេ ដោយមានសំនួរសួរទាក់ទងទៅនឹងអំពីការណាត់ជួបរវាងប្រុស និង ស្រី

   គ. ចែកចាយសេចក្តីបង្រៀននេះជាមួយបងប្រុសរបស់ពួកគេនៅក្នុងគ្រួសាររបស់ពួកគេ ដែលបងប្រុសនោះនៅតែនៅលីវនៅឡើយ

# មេរៀនទី៣

## តារាង--ការបំផ្លាញសេចក្តីស្រលាញ់




សូមពន្យល់ថា ការរួមភេទមុនពេលរៀបការ (អាចជាការរួមភេទ ឬក៏ ការប៉ះពាល់មិនសមរម្យខាងរូបកាយ) នឹងរវាំងយ៉ាងខ្លាំងនូវទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់ ។ វាក៏នឹងកសាងនូវជញ្ជាំងមួយនៃភាពជាប់ទោសរវាងអ្នកទាំងពីរ ។ នេះនឹងធ្វើអោយកាន់តែពិបាកសំរាប់ពួកគេក្នុងការទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកដោយចំហ ។ ពួកគេទាំងពីរនឹងចាប់ផ្តើមមានអារម្មណ៏ឯកការ ដោយព្រោះទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់ និង មិត្តភ័ក្តិរបស់ពួកគេបានរាំងស្ទះ ។ ចង្អុលបង្ហាញនូវសេចក្តីស្រលាញ់នោះ មិនមែនការរួមភេទខាងរូបកាយនោះទេ ដែលចងយើងនៅជាប់គ្នា ហើយ ជំរុញអោយយើងបង្កើតនូវទំនាក់ទំនងដោយសេចក្តីស្រលាញ់ដ៏ជិតស្និទ្ធ ។

# មេរៀនទី៣

## តារាង--ការបង្កើតនូវសេចក្តីស្រលាញ់




គោលបំណងនៃតារាងនេះគឺដើម្បីបង្ហាញនូវគំរូតាមបែបព្រះគម្ពីរ នៃការបង្កើតទំនាក់ទំនងសេចក្តីស្រលាញ់ដែលមានសុខភាពល្អ ជាមួយនឹងមនុស្សដ៏ទៃទៀត ដែលមានភេទផ្ទុយពីគ្នា ។

វិធីដ៏ល្អបំផុតគឺដើម្បីបង្កើតនូវទំនាក់ទំនងដ៏ជិតស្និទ្ធមួយជាមួយនឹងមិត្តរបស់អ្នក គឺថាសំរាប់អ្នកពីរខិតជិតទៅរកព្រះជាម្ចាស់ ។ តារាងបង្ហាញថា ខណៈដែលអ្នកទាំងពីរដាក់ព្រះជាម្ចាស់មុនគេបង្អស់នៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងខិតទៅជិតព្រះជាម្ចាស់ ហើយ ខិតទៅជិតនឹងគ្នាទៅវិញទៅមកដែរ ។ សូមពន្យល់ថា យើងកំពុងនិយាយគ្នាអំពីសេចក្តីអាកាពេ ។

# មេរៀនទី៣

## តារាង--ជំលោះក្នុងការជួបណាត់គ្នារវាងប្រុស និង ស្រី

#1




#2




សូមប្រើតារាងទាំងនេះ ដើម្បីបញ្ជាក់អះអាងថា តើមានអ្វីកើតឡើង ប្រសិនបើមិត្តរបស់អ្នកមិនមែនជាគ្រីស ឬ ប្រសិនបើមិត្តរបស់អ្នកមិនចាប់អារម្មណ៏នៅក្នុងការខិតទៅជិតព្រះជាម្ចាស់ ។ អ្នកអាចខិតទៅជិតព្រះជាម្ចាស់ (រូបទី១), ប៉ុន្តែប្រសិនបើពួកគេមិនចង់ នោះការខិតទៅជិតព្រះជាម្ចាស់ខ្លាំងប៉ុណ្ណារបស់អ្នក ការឃ្លាតចេញឆ្ងាយពីមិត្តរបស់អ្នកក៏កាន់ធំប៉ុណ្ណឹងដែរ ។ តែប្រសិនបើអ្នកសំរេចចិត្តបង្កើតនូវទំនាក់ទំនងដ៏ស៊ីជំរៅមួយជាមួយនឹងមិត្តរបស់អ្នក នោះអ្នកនឹងឃ្លាតឆ្ងាយកាន់តែខ្លាំងពីព្រះជាម្ចាស់ (សូមមើលរូបទី២) ។

# មេរៀនទី៤

## ការរៀបអាពាហ៍ពិពាហ៍

**១. សេចក្តីពិតដែលគន្លឹះនៅក្នុងព្រះគម្ពីរ**

ខ្ញុំត្រូវតែដើរតាមគំរូរបស់ព្រះជាម្ចាស់ ដើម្បីឱ្យទទួលបាននូវអាពាហ៍ពិពាហ៍ដ៏មានជោគជ័យមួយបាន ។

**២. ខគម្ពីរគន្លឹះ សុភាសិត ១៩:១៤**

ផ្ទះសំបែង និង ទ្រព្យសម្បត្តិជាមរតកមកពីឪពុក តែប្រពន្ធដែលឆ្លៀវឆ្លាត នោះហើយជាអំណោយទានមកពីព្រះជាម្ចាស់ ។

**៣. សំភារៈសិក្សាយោងសំរាប់សិស្ស**

ទំព័រទី ១៣ និង ១៤ នៅក្នុងសៀវភៅរបស់សិស្សមានភ្ជាប់នៅក្នុងមេរៀននេះ ។

**៤. ឯកសារយោងផ្សេងៗទៀត**

យើងសូមផ្តល់ជាគំនិតយ៉ាងខ្លាំងដល់ គឺសូមអ្នកអានសៀវភៅមានចំណងជើងថា *ខ្ញុំរៀបការជាមួយអ្នក* ដោយលោកគ្រូ **Walter Trobisch** (ហាពើ និង រ៉ូ រោងបោះពុម្ព) ។ គោលគំនិតភាគច្រើននៃមេរៀននេះ ចេញមកពីសៀវភៅដែលងាយស្រួលអាន និង ដ៏ឧត្តមនេះ ។ អ្នកប្រហែលជាចង់ដាក់ច្បាប់ចំលងពីរបីក្បាលខ្លះនៅក្នុងបណ្ណាល័យ ហើយលើកទឹកចិត្តឱ្យសិស្សអានវា ដែលផ្នែកមួយជាជំនួយដល់វគ្គសិក្សារបស់ពួកគេ ។

**៥. អាពាហ៍ពិពាហ៍ និង ១កូរិនថូស ៧**

សូមឱ្យសិស្សយកចេញនូវគំរោងកិច្ចការទី៣ ដើម្បីប្រើនៅក្នុងថ្នាក់ពិភាក្សាសំរាប់ថ្ងៃនេះ

**៦. អាពាហ៍ពិពាហ៍តាមបែបព្រះគម្ពីរ**

អ្នកប្រហែលជាអ្នកមានថ្នាក់រៀននៅថ្ងៃនេះ ប្រហែលជារវៀងធូរបន្តិច ។ សូមព្យាយាមចំណាយពេលបន្តិចដើម្បីឆ្លើយទៅនឹងសំនួររបស់ពួកគេ ស្តីពីអាពាហ៍ពិពាហ៍ ។ នៅពេលឆ្លើយសំនួររបស់ពួកគេរួចហើយ សូមព្យាយាមផ្តើតទៅលើអ្វីដែលព្រះគម្ពីរថែងអំពីសំនួរទាំងអស់នេះស្តីពីអាពាហ៍ពិពាហ៍ ។ សូមព្យាយាមរក្សានូវគំនិតរបស់អ្នកអោយឆ្ងាយពីរូបភាពនេះតាមដែលអាចធ្វើទៅបាន ។

**៧. សំនួរនានាស្តីអំពីអាពាហ៍ពិពាហ៍**

ត្រូវប្រាកដថា ពួកគេមិនច្រឡំក្នុងការសួរសំនួរដែលមិនប្រាកដនោះឡើយ ។ ប្រសិនបើសំនួរមានលក្ខណៈពិបាកយល់ គ្រាន់តែប្រាប់ពួកគេថា (" ចុះប្រសិនបើ") ធ្វើសំនួរវិញ ។

**៨. កិច្ចពិភាក្សា**

កុំអោយចូលទៅដល់ការពិភាក្សាស្តីពីការលែងលះគ្នា និង រៀបការម្តងទៀតឡើយ ។ សូមប្រាប់ពួកគេថា អ្នកនឹងឆ្លើយនូវសំនួរទាំងអស់នេះជាលក្ខណៈបុគ្គលវិញ រឺ ឯកជនវិញ ។ ប្រសិនបើពួកគេចង់ពិភាក្សាចំនុចនេះនៅក្នុងថ្នាក់ ចូរនាំពួកគេទៅកាន់សេចក្តីពិតដែលជាគន្លឹះនៅក្នុងព្រះគម្ពីរសំរាប់ថ្ងៃនេះ ។

**៩. សកម្មភាពផ្លូវភេទពីអតីតកាល**

យូរៗម្តងអ្នកនឹងអាចមានសិស្សពិភាក្សាសកម្មភាពផ្លូវភេទអតីតកាលរបស់ពួកគេ ។ កុំអនុញ្ញាត្តិអោយពួកគេរៀបរាប់អតីតកាលផ្លូវភេទរបស់ពួកគេកេងប្រវ័ញ្ចនៅក្នុងថ្នាក់ឡើយ ។ ប្រសិនបើពួកគេពួកគេចាប់ផ្តើមធ្វើអញ្ចឹង សូមអោយពួកគេឈប់និយាយភ្លាម ។

**១០. ផែនការរបស់ព្រះជាម្ចាស់សំរាប់អាពាហ៍ពិពាហ៍ (១០-១៥នាទី)**

សូមយកពេលមុនថ្នាក់រៀនបន្តិច ដើម្បីបញ្ចប់ចំនុចទី៥ "គំរូរបស់ព្រះជាម្ចាស់សំរាប់អាពាហ៍ពិពាហ៍ដែលមានជោគជ័យ" សូមមើលទំព័រ១៤ នៃសៀវភៅសិស្សសំរាប់ព័ត៌មានបន្ថែមស្តីពីចំនុចនេះ ។ សៀវភៅរបស់លោក Walter Trobisch និយាយយ៉ាងច្រើនស្តីពីចំនុចទាំងនេះ ។

**១១. តើត្រៀមរៀបចំខ្លួនហើយឬនៅសំរាប់អាពាហ៍ពិពាហ៍? (៥-១០នាទី)**

សូមពិភាក្សាបញ្ហានេះ "តើនៅពេលណា ដែលមនុស្សម្នាក់ត្រៀមរៀបចំខ្លួនសំរាប់អាពាហ៍ពិពាហ៍?" (ចំនុចទី២) សូមអោយសិស្សចែកចាយនូវចំលើយរបស់ពួកគេចំពោះសំនួរនេះចេញពីគំរោងកិច្ចការទី៤ សំនួរទី២ ។

**១២. អាពាហ៍ពិពាហ៍តាមគំរូរបស់ព្រះជាម្ចាស់**

អ្នកប្រហែលជាចង់ពិភាក្សាលើសំនួរផ្សេងៗទៀតចេញពីគំរោងកិច្ចការទី៣ និង ទី៤ ស្តីពីអាពាហ៍ពិពាហ៍ ។

**១៣. ការអនុវត្តន៏សំរាប់ផ្ទាល់ខ្លួន**

សូមផ្តើតលើការអនុវត្តន៏សំរាប់ផ្ទាល់ខ្លួន ស្តីពីការបង្កើតនូវឥរិយាបថតាមគំរូព្រះគម្ពីរចំពោះផ្លូវភេទ ។ សំរាប់អស់អ្នកដែលបានរៀបការរួចហើយ សូមឱ្យពួកគេរាយនូវវិធីនានានៃការបង្កើត និង ការបង្ហាញសេចក្តីស្រលាញ់នៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ ។ សូមសង្កត់បញ្ជាក់ពីសារសំខាន់នៃភាពបើកចំហរ និង ស្មោះត្រង់ជាមួយប្តី ឬ ប្រពន្ធ ។

**១៤. កិច្ចការសំរាប់ក្នុងថ្នាក់**

ក. សូមដាក់ពិន្ទុ និង ចំណាត់ថ្នាក់លើគំរោងកិច្ចការទី៤ នៅចុងបញ្ចប់នៃថ្នាក់រៀននេះ ។

# មេរៀនទី៥

## ការប្រលង

១.	សូមណែនាំវគ្គសិក្សាបន្ទាប់ថា នឹងត្រូវបញ្ចប់អ្វីខ្លះ

ក. សូមចែកជូនដល់សិស្សម្នាក់ៗនូវក្រដាសថតចំលងទទេនៃតារាងកិច្ចការនៅក្នុងថ្នាក់ ។ សូមប្រាប់ពួកគេនូវថ្ងៃខែឆ្នាំ សំរាប់រាល់ប្រលងតូចៗ គំរោងកិច្ចការ និង ប្រលង ធំ ។

២.	សូមធ្វើប្រលងមួយសំរាប់វគ្គសិក្សានេះ

៣.	ប្រសិនបើអ្នកមិនទាន់បានធ្វើវារួចរាល់នៅឡើយទេ សូមចែកត្រឡប់នូវការប្រលងតូចៗ និង គំរោងកិច្ចការនានា ដែលអ្នកបានដាក់ពិន្ទុអោយ ។